# ដំណឹងជ្រើសរើសបុគ្គលិក

**អង្គការតំលៃស្ត្រី** គឺជាអង្គការគ្រីស្ទបរិស័ទក្នុងស្រុកមួយក្នុងរាជធានីភ្នំពេញ ដែលធ្វើការជួយទៅដល់ស្ត្រីរងគ្រោះ និង ត្រូវបានគេរំលោភបំពាននៅតាមសេវាកំសាន្តដូចជាបៀហ្គាឌិន និង ខារ៉ាអូខេក្នុងប្រទេសកម្ពុជា។

**និមិត្តៈ** លើកកំពស់ស្ត្រីដែលត្រូវបានកេងប្រវញ្ច័នៅតាមរង្គសាល បៀរហ្គាឌិន និងផ្ទះបន ក្នុងប្រទេសកម្ពុជាអោយរស់នៅដោយស្មើភាពគ្នា មានសេចក្តីថ្លៃថ្នូរ និងក្តីសង្ឃឹម។

**បេសកកម្មៈ**លើកកំពស់បរិយាកាសការងារ ដើម្បអោយរួចផុតពីការកេងប្រវញ្ច័ និង រំលោភបំពានទៅដល់ស្ត្រី តាមរយៈការប្រឹក្សាយោបល់ បញ្ជូនទៅរៀនជំនាញ និងជំរើសការងារថ្មី ។

**អង្គការតំលៃស្ត្រី** គឺកំពុងត្រូវការជ្រើសរើសបេក្ខជន ជាជនជាតិខ្មែរដែលមានសមត្ថភាព និង មានបំណងចង់បំពេញការងារនូវមុខតំណែងដូចខាងក្រោមនេះ៖

| មុខតំណែង: | គ្រូបណ្តុះបណ្តាលជំនាញផ្នែកសំអាងការ និង កែសម្ផស្ស |
|---|---|
| តំបន់: | ភ្នំពេញ |

**ការទទួលខុសត្រូវ និង ភារៈកិច្ច**

- ថែរក្សា រៀបចំសំភារៈតុបតែងមុខ កែសម្ផស្ស និងសំអាងការឲ្យបានស្អាត មានសណ្តាប់ធ្នាប់
- ស្នើរសុំទិញសំភារៈបន្ថែមមុនពេលប្រើប្រាស់អស់ ឬ ពេលសំភារៈចាស់ត្រូវខូច
- បន្តធ្វើការជាមួយឧបករណ៍ដែលស្អាតមានអនាម័យ ដោយកំចាត់មេរោគបានត្រឹមត្រូវល្អដូចជា កន្ត្រៃ ក្រាស់ ដង្កៀបសក់ និង ឧបករណ៍ផ្សេងៗទៀត ។
- ធ្វើកំណត់ត្រាបញ្ជីប្រាក់ចំនូល និងចំណាយដើម្បីប្រគល់អោយគណនេយ្យជារៀងរាល់ថ្ងៃ
- ដើរសំអាងការទៅតាមការព្រមព្រៀងរបស់ហាង និងអតិថិជន ។
- ផ្សព្វផ្សាយព័ត៌មានដល់អតិថិជនអំពីសេវាកម្មរបស់ សំអាងការតំលៃស្ត្រី ដែលមាន ដូចជា សេវាកម្មតុបតែងមុខ កែសម្ផស្ស និង សំអាងការជាដើម។រៀបចំប្លង់មេរៀន និង បង្កើតកាលវិភាគបង្រៀនសិស្ស
- ធ្វើការបណ្តុះបណ្តាលដល់សិស្សដោយផ្អែកតាមកាលវិភាគ និងមេរៀនដែលបានរៀបចំ
- បញ្ជូនតារាងវត្តមានសិស្សទៅកាន់បុគ្គលិកសង្គមកិច្ចជារៀងរាល់ខែ
- មានជាមតិយោបល់ល្អៗ ដើម្បីអភិវឌ្ឍ និងស្ថាបនាលើចំនុចខ្វះខាតរបស់សិស្ស
- កំណត់ និងទិញឧបករណ៍រៀនរបស់សិស្សអោយទាន់ពេលវេលា
- រំលឹកកម្មវិធីសិក្សាដល់សិស្សជារៀងរាល់ខែ
- ធ្វើការស្រាវជ្រាវ ដើម្បីអភិវឌ្ឍន៍ជំនាញ និងបច្ចេកទេសថ្មីៗផ្ទាល់ខ្លួនបន្ថែមទៀត
- បញ្ជូនពត៍មានដែលមិនប្រក្រតីរបស់សិស្សទៅកាន់បុគ្គលិកសង្គមកិច្ច រឺ បុគ្គលិកសម្របសម្រួល គំរោងមេអំបៅ ដើម្បីស្វែងរកដំណោះស្រាយទាន់ពេលវេលា
- រៀបចំកម្មវិធីប្រលងលើកទី១ និងប្រលងបញ្ចប់

| |
|---|
| ០ បន្តគាំទ្រ និងផ្តល់គំនិតកែលំអដល់សិស្ស ដែលត្រូវការជំនួយពេលបញ្ចប់វគ្គ។<br>០ |
| **លក្ខខ័ណនៃការជ្រើសរើស** |
| ○ ត្រូវមានបទពិសោធខាងបង្រៀនសិស្ស ឬក៏ធ្លាប់បើកហាងខ្លួនឯងយ៉ាងតិចរយៈពេល ១ឆ្នាំ។<br>○ ត្រូវចេះអត់អត់ធ្មត់, ស្មោះត្រង់ និង មានគំនិតច្នៃប្រឌិតថ្មីៗចំពោះអង្គការ និង ក្រុមការងារ។<br>○ ប្រកាន់ភ្ជាប់នូវបទបញ្ជាផ្ទៃក្នុង និង បទបញ្ជាជាផ្លូវការរបស់ អង្គការតំលៃស្ត្រី ដោយរួមទាំងច្បាប់ការពារងាយរងគ្រោះ និងកុមារផងដែរ។<br>○ ប្រកាន់ភ្ជាប់នូវឥរិយាបថវិជ្ជាមានចំពោះអង្គការ ការងារ និង មិត្តរួមការងារ<br>○ ចេះចុះចូលជាមួយក្រុមការងារ គោរពអតិថិជន និង ភ្ញៀវដទៃទៀត<br>○ ចេះរៀបចំចាត់ចែង មានសមត្ថភាពក្នុងការងារ<br>○ មានសណ្តាប់ធ្នាប់ល្អ និង អនាម័យខ្ពស់<br>○ ចេះរក្សាការសំងាត់យ៉ាងតឹងរឹងបំផុតចំពោះការងារនៅក្នុងអង្គការ ការងារបុគ្គលិក បញ្ហា រឺក៏ពត៌មានលម្អិតរបស់អតិថិជន |

ប្រសិនបើបេក្ខជនមានចំណាប់អារម្មណ៍ទៅលើមុខតំណែងមួយនេះសូមប្រវត្តិរូបសង្ខេបមកកាន់អង្គការតំលៃស្ត្រី ផ្ទះលេខ ២C ផ្លូវ ៤៥ BT សង្កាត់បឹងទំពុន ខ័ណ្ឌមានជ័យ រាជធានីភ្នំពេញ ឬទំនាក់ទំនងលេខទូរស័ព្ទ៖
០៨៩ ២៧០ ៤៧០/០១៦ ៣៩៤ ០០៦